# តារាងស្ដីពីព័ត៌មានរបស់គម្រោង

លេខPIP : 811

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)

## ផ្នែក ក

១. ឈ្មោះគម្រោង : គ្រប់គ្រងព្រៃឡង់សម្រាប់ផលប្រយោជន៍សហគមន៍មូលដ្ឋាន

២. កាលបរិច្ឆេទគម្រោង

កាលបរិច្ឆេទចាប់ផ្ដើមគម្រោង 31/01/16

កាលបរិច្ឆេទបញ្ចប់គម្រោង 31/12/18

៣. ចំណាយគម្រោងសរុប $399,991

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

RESPONSIBLE UNIT Forestry Administration

អង្គភាពទទួលខុសត្រូវ រដ្ឋបាលព្រៃឈើ

៥. ស្ថានភាពគម្រោង គម្រោងដែលបានបញ្ចប់

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងជំនួយបច្ចេកទេស

៧. ប្រភពហិរញ្ញប្បទាន៖ ជំនួយឥតសំណង

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

គម្រោងនឹងជួយដល់ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនមូលដ្ឋានក្នុងតំបន់គោលដៅ តាមរយៈការគាំទ្រលើសកម្មភាពលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ។ គម្រោងក៏ជួយផងដែរដល់ការទប់ស្កាត់ការកាប់រានព្រៃឈើ តាមរយៈការល្បាតរបស់មន្ត្រីជំនាញ និង ការគាំទ្រការល្បាតរបស់សហគមន៍។ ជាងនេះទៅទៀត គម្រោងក៏បានផ្ដោត ដល់ការលើកកម្ពស់សមត្ថភាពរបស់មន្ត្រីរដ្ឋបាល ព្រៃឈើ បរិស្ថានលើជំនាញផលិតផែនទី និងការកសាងសមត្ថភាព ប្រជាពលរដ្ឋស្ដីពីការប្រែប្រួលអាកាសធាតុ។

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍនវិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

បរិស្ថាន និងការអភិរក្ស Forestry Sector

**១២. ទីតាំងអនុវត្តគម្រោង** (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

ក្រចេះ, កំពង់ធំ, ស្ទឹងត្រែង,

**១៣. គោលបំណងរបស់គម្រោង** (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

គោលដៅរួមរបស់គម្រោងគឺ ការពារព្រៃក្នុងតំបន់គម្រោងដើម្បីអាចផ្តល់ជាប្រយោជន៍ដល់ ប្រជាជនសហគមន៍មូលដ្ឋាន ដែលពឹងផ្អែកលើធនធានព្រៃឈើ។ សម្រាប់គោលបំណងជាក់លាក់នៃគម្រោងគឺនឹងជួយបង្កើន ជីវភាពដល់ប្រជាជនដែលរស់នៅក្នុង និងជុំវិញតំបន់អនុវត្តគម្រោង ព្រមទាំងពង្រឹងការអនុវត្តច្បាប់ដើម្បីធានាការការពារធនធានព្រៃឈើឲ្យនៅគង់វង្ស។

**១៤. ការពិពណ៌នាអំពីគម្រោង** (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

គម្រោងគ្រប់គ្រងព្រៃឡង់សម្រាប់ផលប្រយោជន៍ប្រជាជនមូលដ្ឋាន គឺអនុវត្តដោយរដ្ឋបាលព្រៃឈើ ហើយគម្រោងនេះរួមចំណែកសំខាន់បំផុតដល់ការគាំទ្រសហគមន៍ដែលគម្រោងបានជ្រើសរើសក្នុងទីតាំងអនុវត្តគម្រោងក្នុងខេត្តទាំងបី តាមរយៈការស្វែងរកប្រភពចំណូលផ្សេងៗដល់សហគមន៍ដើម្បីឲ្យពួកគាត់ទទួលបានចំណូលបន្ថែម និងក៏ធ្វើការពង្រឹងការអនុវត្តច្បាប់ តាមរយៈការគាំទ្រដល់ការល្បាតព្រៃរបស់សហគមន៍ និងរដ្ឋបាលព្រៃឈើមូលដ្ឋាន ដើម្បីធានាដល់ការការពារធនធានព្រៃឈើ។

**១៥. យុត្តិកម្មលើគម្រោង** (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

គោលបំណងនៃគម្រោងគឺលើកកម្ពស់ជីវភាពប្រជាជន ដែលស្របទៅនឹងគោលបំណងរបស់រដ្ឋាភិបាលដូចគ្នា។ ជាងនេះទៅទៀត ការការពារព្រៃឈើគឺនឹងជួយដល់ការលើកកម្ពស់ជីវភាពប្រជាជនដែលរស់នៅក្នុង និងជុំវិញតំបន់ព្រៃឡង់ ដែលពួកគាត់ ភាគច្រើនពឹងផ្អែកលើធនធានព្រៃឈើ។ ការការពារព្រៃឈើ ក៏មានសារៈសំខាន់ចំពោះប្រព័ន្ធអេកូឡូស៊ីផងដែរ ព្រោះតំបន់ព្រៃឡង់ គឺមានសារៈសំខាន់សម្រាប់មនុស្ស និងជាជម្រកសត្វព្រៃ។

**១៦. ផលប្រយោជន៍របស់គម្រោង** (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

គម្រោងនេះនឹងផ្តល់ប្រយោជន៍ដល់រដ្ឋបាលព្រៃឈើ ប្រជាជនក្នុងភូមិគោលដៅ ព្រមទាំងអ្នកពាក់ព័ន្ធក្នុងវិស័យព្រៃឈើនានា។

**១៧. ការសិក្សាសមិទ្ធិលទ្ធភាព**

| | |
|---|---|
| តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? | **មាន** |
| ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? | **មិនទាន់ចាប់ផ្តើម** |

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

គម្រោងនឹងមិនមានផលប៉ះពាល់ដល់ប្រជាជន និងបរិស្ថានជុំវិញនោះទេ តែវានឹងជួយដល់ការការពារព្រៃឈើតាមរយៈការល្បាត និងការលើកម្ពស់ជីវភាពតាមរយៈការរកផលអនុផលព្រៃឈើ និងសកម្មភាពលើកកម្ពស់ជីវភាពដោយមានការគាំទ្រពីគម្រោងវិញ។

**១៩. ការប្រែប្រួល អាកាសធាតុ**

| | |
|---|---|
| ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? | **មាន** |
| ប្រសិនបើទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ សូមជ្រើសរើស | **ការបន្សាំ** |

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ |
|---|---|---|

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

| | |
|---|---|
| តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? | **មាន** |
| ប្រសិនបើ ទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយ សូមជ្រើសរើស | **ការបង្ការ** |

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**គម្រោងនឹងធ្វើឲ្យមានការប៉ះពាល់ដល់តួនាទីបុរស និងស្ត្រីឡើយ ហើយស្ត្រីត្រូវបានលើកទឹកចិត្តឲ្យចូលរួមក្នុងសកម្មភាពគម្រោង។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**មន្ត្រីដែលទទួលខុសត្រូវក្នុងគម្រោងមានជំនាញគ្រប់គ្រាន់ក្នុងការអនុវត្តគម្រោង។**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

**គម្រោងបានកំណត់អាទិភាពបីសំខាន់គឺ ជួយលើកកម្ពស់ជីវភាពប្រជាជនតាមរយៈការគាំទ្រជាច្រើនរួមមាន ការជួយដល់ក្រុមជំទឹក ក្រុមសន្សំ ក្រុមឃុំ ការជួយសាងសង់ស្រះទឹក អណ្តូង សូឡា ដែលអាចផ្តល់ជាប្រភពចំណូលបន្ថែម ក៏ដូចជាកាត់បន្ថយ ការចំនាយរបស់សមាជិកសហគមន៍ ការកសាងសមត្ថភាពដល់មន្ត្រី និងប្រជាជនមូលដ្ឋាន និងការការពារព្រៃឈើ តាមរយៈការល្បាត ព្រៃពីសំណាក់សហគមន៍ព្រៃឈើ និងរដ្ឋបាលព្រៃឈើ។**

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

1

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

**គម្រោងទទួលបានការគាំទ្រពីស្ថានទូតជប៉ុន និងត្រូវអនុវត្តរយៈពេល២ឆ្នាំ ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៨។**

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2017 | | 2018 | 2019 | 2020 | 2021 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2019-2021 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 25.0 | 19.7 | 16.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 11.0 | 11.0 | 7.2 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| សម្ភារៈនិងរដ្ឋបាល | 2.8 | 2.3 | 2.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 11.2 | 6.4 | 6.8 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 180.3 | 155.9 | 96.4 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 12.2 | 12.3 | 8.2 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 168.1 | 143.6 | 88.2 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 205.3 | 175.6 | 112.4 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2017 | | 2018 | 2019 | 2020 | 2021 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2019-2021 | |
| | | | | | | | | |
| **ចំណូលពីគម្រោង** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ថវិកាជាតិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ** | 205.1 | 175.6 | 112.4 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| Japan | 205.1 | 175.6 | 112.4 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់** | 205.1 | 175.6 | 112.4 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម** | 0.2 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: